ដោយ លូស៊ី ស្ទីវ៉ែនសុន អ៊ីវែល
( ផ្អែកទៅលើដំណើររឿងពិត )

# ត្បូងពណ៌ស្វាយដ៏ភ្លឺចែងចាំង

*ប្រសិនបើនាងប្រាប់ការពិត តើគាត់នឹងខឹងនឹងនាងដែរឬទេ ?*

*ដំណើររឿងនេះបានកើតឡើងនៅប្រទេស ហូឡង់ ។*

ម៉ារីបានបើកប្រអប់គ្រឿងអលង្ការរបស់នាង ដើម្បីមើលត្បូងដ៏ស្រស់ស្អាតរបស់នាង ។ នាងបានកាន់វាម្តងមួយៗនៅក្នុងដៃរបស់នាង ។ ពណ៌ក្រហម បន្ទាប់មកពណ៌បៃតង បន្ទាប់មកទៀតពណ៌ស ។

លោកយាយបានគោះទ្វារបន្ទប់គេង ។ « ទៅបាននៅ ? »

« ចាស! » ម៉ារីបានដាក់ត្បូងទាំងនោះចូលទៅក្នុងប្រអប់របស់នាងវិញដោយប្រុងប្រយ័ត្ន ។

លោកយាយបាននាំម៉ារីទៅបណ្ណាល័យ ។ ប៉ុន្តែមិនត្រឹមតែទៅមើលសៀវភៅប៉ុណ្ណោះទេ ។ វាមានការដាក់តាំងបង្ហាញត្បូងពិសេសនៅទីនោះ ! ម៉ារីរំភើបយ៉ាងខ្លាំង ។

នៅពេលដែលរថយន្តក្រុងរបស់ពួកគេបានទៅដល់បណ្ណាល័យ ម៉ារី និងលោកយាយបានដើរចូលទៅខាងក្នុង ។ ពួកគេឃើញតុដាក់ត្បូងដ៏ស្រស់ស្អាតជាច្រើន ។ ត្បូងខ្លះមានពន្លឺ និងរលោង ។ ខ្លះទៀតមានរូបរាងគួរឲ្យចាប់អារម្មណ៍ ។

« មើលអាមួយនេះ ! » លោកយាយចង្អុលទៅគ្រីស្តាល់ដ៏ធំមួយ ។ វាមានពន្លឺពណ៌ខៀវតិចៗនៅជាប់នឹងវា ។

តុមួយទៀតមានត្បូងរាងមូលតូចៗជាច្រើន ។ ម៉ារី បានមើលទៅពណ៌ទាំងអស់ ។ នៅចុងបញ្ចប់គឺជាត្បូងពណ៌ស្វាយ រាងតូច និងមានពន្លឺភ្លឺ និងរលោងចែងចាំង ។





*ខ្ញុំមិនទាន់មានត្បូងពណ៌ស្វាយនៅឡើយទេ* ម៉ារីបានគិត ។ វានឹងល្អឥតខ្ចោះសម្រាប់ការសន្សំទុករបស់នាង ។

ម៉ារីបានសម្លឹងមើលជុំវិញខ្លួន ។ លោកយាយបាននៅឯតុមួយទៀត ។ គ្មាននរណាម្នាក់នៅក្បែរនោះទេ ។ ហើយគ្មាននរណាម្នាក់នឹងដឹងថាបាត់ត្បូងតូចនេះទេមែនទេ ?

ម៉ារីបានយកត្បូង ហើយដាក់វាទៅក្នុងហោប៉ៅរបស់នាង ។

យប់នោះ ម៉ារីយកត្បូងពណ៌ស្វាយដាក់នៅក្នុងប្រអប់គ្រឿងអលង្ការរបស់នាងដោយសុវត្ថិភាព ហើយនាងបានចូលគេង ។

« ត្រៀមខ្លួនសម្រាប់ពេលវេលារឿងនិទានហើយឬនៅកូន ?» ប៉ាអង្គុយនៅលើគ្រែ ហើយបានបើកសៀវភៅទស្សនាវដ្តី *ប្រិយមិត្ត* ។

ម៉ារីបានលូនចូលទៅក្នុងភួយរបស់នាង ហើយបានស្តាប់រឿងនោះ ។ ដំណើររឿងនេះគឺអំពីក្មេងប្រុសម្នាក់ដែលបានប្រែចិត្តក្រោយពីគាត់បានធ្វើការជ្រើសរើសខុស ។

ពេលប៉ាអាន ម៉ារីមានអារម្មណ៍ថា ពោះរបស់នាង កំពុងរមូលទៅជាចំណង ។ នាងបានផ្អៀងទៅចំហៀង បន្ទាប់មកក្រឡាប់ខ្នើយរបស់នាង ។ ប៉ុន្តែនាងមិនមានអារម្មណ៍ល្អសោះ ។ ហើយនាងមិនអាចឈប់គិតអំពីត្បូងពណ៌ស្វាយបានទេ ។

ប៉ាបានបញ្ចប់រឿងនេះ ។ « កូនមិនអីទេ មែនទេ ? »

ម៉ារីមិនដឹងថាត្រូវធ្វើអ្វីឡើយ ។ ប្រសិនបើនាងប្រាប់ប៉ា គាត់អាចនឹងខឹង ។

ប៉ុន្តែប្រហែលជាគាត់អាចនឹងដឹងអំពីរបៀបដើម្បីជួយ ។

បន្តិចម្តងៗ ម៉ារីបានលូនចេញពីគ្រែ ហើយបានយកត្បូងពណ៌ស្វាយចេញពីប្រអប់របស់នាង ។ « កូនបានយករបស់នេះចេញពីបណ្ណាល័យថ្ងៃនេះ » ។ ទឹកភ្នែកបានហូរចេញពីភ្នែករបស់ម៉ារី ។ « កូនសោកស្តាយខ្លាំងណាស់ » ។

លោកប៉ាបានឱបនាងយ៉ាងណែន ។ « វាតែងតែជាការល្អក្នុងការប្រាប់ប៉ាអំពីការពិត។ ប៉ាមានមោទនភាពចំពោះភាពក្លាហានរបស់កូននៅក្នុងការមានភាពស្មោះត្រង់ » ។

ពោះរបស់មារី ចាប់ផ្តើមមានអារម្មណ៍ល្អឡើងវិញ ។ ប៉ាមិនខឹងទេ !

« ហើយដោយសារព្រះយេស៊ូវ នោះយើងអាចប្រែចិត្តបាន ។ ប៉ាបាននិយាយថា ដូចនៅក្នុងរឿងនេះដែរ » « ហេតុអ្វីយើងមិនយកត្បូងនេះទៅឲ្យបណ្ណាល័យវិញទៅ ? »

ម៉ារីបានប្រឹងបិទភ្នែករបស់នាងជិត ។ « ទេ ! ពួកគេនឹងខឹង » ។

ប៉ាដាក់ដៃលើស្មារបស់នាង ។ « គេប្រហែលជាខឹងបន្តិច ។ ប៉ុន្តែប៉ាគិតថាពួកគេនឹងរីករាយដែលកូនបានឲ្យវាទៅវិញ ។ ហើយវានឹងធ្វើឲ្យកូនមានអារម្មណ៍កាន់តែប្រសើរឡើងផងដែរ » ។

ម៉ារីបានដកដង្ហើមធំ ហើយបានងក់ក្បាលយល់ព្រម ។ « ចាស » ។

ម៉ារីបានទាញយកក្រដាសមួយសន្លឹក ហើយបានចាប់ផ្តើមសរសេរលិខិតមួយ ។ នាងបានសរសេរថា « ខ្ញុំសូមទោសចំពោះការយករបស់នេះ » ។ ខ្ញុំមិនគួរធ្វើរឿងបែបនេះទេ ។ ខ្ញុំចង់កែខ្លួនឲ្យត្រឹមត្រូវវិញ » ។

នាងបានដាក់លិខិតនោះទៅក្នុងស្រោមសំបុត្រមួយ ។ បន្ទាប់មកនាងក៏ដាក់ត្បូងពណ៌ស្វាយតូចនោះទៅក្នុងស្រោមសំបុត្រផងដែរ ។

ប៉ាបាននិយាយថា ៖ « យើងនឹងយករបស់នេះទៅវិញនៅថ្ងៃស្អែក » ។ « តើកូនមានអារម្មណ៍បែបណាឥឡូវនេះ ? »

ម៉ារីបាននិយាយថា « ប្រសើរហើយ » ។ « នៅតែមានរឿងមួយទៀតដែលកូនត្រូវធ្វើ » ។

ម៉ារីបានលុតជង្គង់នៅក្បែរគ្រែគេងរបស់នាង ហើយអធិស្ឋាន ។ នាងបាននិយាយថា « ទូលបង្គំសូមទោសដែលទូលបង្គំបានយកត្បូងនោះ » ។ « ទូលបង្គំនឹងមិនលួចទៀតទេ ។ សូមអរព្រះគុណព្រះអង្គដែលបានជួយខ្ញុំឲ្យមានភាពក្លាហាន និងភាពស្មោះត្រង់ » ។

ពេលនាងចូលគេងវិញ ម៉ារីមានអារម្មណ៍សុខសាន្ត ។ ថ្ងៃស្អែកនាងនឹងធ្វើរឿងត្រឹមត្រូវ ។ ហើយនាងបានដឹងថាព្រះវរបិតាសួគ៌ និងព្រះយេស៊ូវនឹងជួយដល់នាង ។ ដោយសារទ្រង់ទាំងទ្វេនោះអ្វីៗគ្រប់យ៉ាងនឹងគ្មានបញ្ហានោះទេ ។ ●